**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ ជូនយោធិននៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សដល់យោធិននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកែសម្រួល និង ដំឡើងប្រាក់បំណាច់មុខងារជូនយោធិននៃកងយោធពលខេមរភូមិន្ទ ដើម្បីធានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាព និងការបង្កើនផលិតភាពការងារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅរៀបចំការកែសម្រួល និង ការដំឡើងប្រាក់បំណាច់មុខងាររបស់យោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៤ .-**

ប្រាក់បំណាច់មុខងាររបស់យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃមុខតំណែងមូលដ្ឋាននិងមុខតំណែងសមមូលជា១៦(ដប់ប្រាំមួយ)ថ្នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | មុខតំណែងមូលដ្ឋាន | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គមេបញ្ជាការ | ១ ៧៥០ ០០០ |
| ២ | អគ្គមេបញ្ជាការរង | ១ ៥០០ ០០០ |
| ៣ | មេបញ្ជាការ យោធភូមិភាគ | ១ ៣០០ ០០០ |
| ៤ | មេបញ្ជាការ កងពលធំ (ឬរងយោធភូមិភាគ) | ៧០០ ០០០ |
| ៥ | មេបញ្ជាការ កងពលតូច (ឬរងកងពលធំ) | ៦០០ ០០០ |
| ៦ | មេបញ្ជាការ កងវរសេនាធំ (ឬរងកងពលតូច) | ៤២០ ០០០ |
| ៧ | មេបញ្ជាការ កងវរសេនាតូច (ឬរងកងវរសេនាធំ) | ៣១០ ០០០ |
| ៨ | មេបញ្ជាការរង កងវរសេនាតូច | ២៥០ ០០០ |
| ៩ | មេបញ្ជាការ កងអនុសេនាធំ | ២១០ ០០០ |
| ១០ | មេបញ្ជាការរង កងអនុសេនាធំ | ១៩០ ០០០ |
| ១១ | មេបញ្ជាការ កងអនុសេនាតូច | ១៨០ ០០០ |
| ១២ | មេបញ្ជាការរង កងអនុសេនាតូច | ១៧០ ០០០ |
| ១៣ | នាយក្រុម | ១៦៥ ០០០ |
| ១៤ | នាយរងក្រុម | ១៦០ ០០០ |
| ១៥ | នាយពួក | ១៥៥ ០០០ |
| ១៦ | យុទ្ធជន | ១៥០ ០០០ |

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រា៥ .-**

មុខតំណែងដទៃទៀតដែលសមមូលនឹងមុខតំណែងមូលដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ផ្អែកលើព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសស្តីពីការតែងតាំង។

**មាត្រា៦ .-**

យោធិនដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងតំណែងនោះ។ ករណីយោធិនដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់។

**មាត្រា៧ ._**

ការកែប្រែចំនួនមុខតំណែងមូលដ្ឋានឬប្រាក់បំណាច់មុខងារដែលមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ._**

យោធិនដែលមានសិទ្ធទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់កងទ័ព
- យោធិនពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- យោធិនដែលទទួលការអនុញ្ញាតច្បាប់ក្នុងចុះផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៩ ._**

ការបញ្ឈប់ការបើកផ្តល់ប្រាក់បំណាច់មុខងារ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម៖

- យោធិនដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- យោធិនដែលមានប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ
- យោធិនដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- យោធិនពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- យោធិនដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

**មាត្រា១០ ._**

របបឧបត្ថម្ភផ្សេងៗរបស់យោធិនក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា១១ ._**

អនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ អនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ និងអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ ត្រូវទុកជានិរាករណ៍ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

**មាត្រា១២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ** **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់** **អូន ព័ន្ធមុនីរ័ត្ន** **ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ